ក

## មាតិកា

## I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រម


២៦-១២-២០១២ - ព្រះរាជក្រម នស/រកម/១២១២/០១១ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិក នៃកិច្ចព្រមព្រៀង ស្តីពី ការបង្កើតវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល ២៤១


### ២-ព្រះរាជក្រឹត្យ


១៥-១២-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៤៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ជូ គីប៊ែង** (JOO KIBYUNG) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **ជូ គីមសាន** (JOO KIM SAN) ២៧៨

១៥-១២-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៤៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **កាង ជុងហ៊ៀន** (KANG JONG HYEON) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ២៧៩

១៩-១២-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៧៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ជាង សៅជុន** (JIANG SHAOJUN) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន ២៨០

១៩-១២-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៧៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លីម ហេខាយ** (LIM VHE KAI) ជនជាតិម៉ាឡេស៊ី សញ្ជាតិម៉ាឡេស៊ី កើតនៅទីក្រុងម៉ាឡាកា ប្រទេសម៉ាឡេស៊ី ដោយប្តូរឈ្មោះជា **លីម ដេម្យេន** (LIM DAMIEN) ២៨១

១៩-១២-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៧៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **គីម ឌីអូនីស៊ីសយ៉ុងវ៉ា** (KIM DIONYSIUS YOUNG WHA) ជនជាតិកូរ៉េ សញ្ជាតិអាមេរិក កើតនៅក្រុងអិនឈើន សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **គីម សុខសាន្ត** ( KIM SOKSAN) ២៨២

២០-១២-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៨១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ អង្គភាព ចំនួន ២០ និង នាយទាហាន នាយទាហានរង ពលទាហាន និង សប្បុរសជន ចំនួន ១.១៦៣ រូប ២៨៣

# II~រាជរដ្ឋាភិបាល

## ១~អនុក្រឹត្យ

៣១-១២-២០១២-អនុក្រឹត្យលេខ ២៧៩ អនក្រ.បក ស្ដីពី ការផ្ទេរឥណទានថវិកា ៣២៨

០១-០១-២០១៣-អនុក្រឹត្យលេខ ០១ អនក្រ.បក ស្ដីពី ការកាត់ដីសរុបទំហំ ៤.៩៩៨,១៣ ហិកតា នៅស្រុកស្នួល ខេត្តក្រចេះ ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ហួត សម្បត្តិ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.៧៩៩ គ្រួសារ និង រក្សាមួយចំណែកជាដីសាធារណៈរបស់រដ្ឋ និង ការផ្ដល់សិទ្ធិលើក្បាលដី ៣៣០

០១-០១-២០១៣-អនុក្រឹត្យលេខ ០២ អនក្រ.បក ស្ដីពី ការកាត់ដីសរុបទំហំ ៥.៨៧៣ ហិកតា នៅស្រុកស្នួល ខេត្តក្រចេះ ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ធី ធី វ៉ាយ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.៥៥៨ គ្រួសារ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ និង ការផ្ដល់សិទ្ធិលើក្បាលដី ៣៣៣

០១-០១-២០១៣-អនុក្រឹត្យលេខ ០៣ អនក្រ.បក ស្ដីពី ការកាត់ដីសរុបទំហំ ២.៦១៥,១៥ ហិកតា នៅស្រុកឆ្លូង ខេត្តក្រចេះ ចេញពីដីព្រៃសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន CASOTIM និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋសរុប ៥៤១ គ្រួសារ និង រក្សាមួយចំណែក ជាដីសាធារណៈរបស់រដ្ឋ និង ការផ្ដល់សិទ្ធិលើក្បាលដី ៣៣៦

០៣-១១-២០១២-អនុក្រឹត្យលេខ **២៣៤៦** ដល់អនុក្រឹត្យលេខ **២៣៦៧** អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៣៣៩

## ២~សារាចរ

០៨-០១-២០១៣-សារាចរលេខ ០១ សរ ស្ដីពី ព្រះរាជពិធីដង្ហែ និង ថ្វាយព្រះភ្លើង គោរពព្រះបរមសព ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និង ឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ ៣៦១

# ព្រះរាជក្រម

នស/រកម/១២១២/០១១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងស្តីពីការបង្កើតវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១២ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១២ នាសម័យប្រជុំពេញអង្គលើកទី២ នីតិកាលទី៣ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្ដីពី
# ការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជា សមាជិក នៃកិច្ចព្រមព្រៀងស្ដីពីការបង្កើត វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល

**មាត្រា ១.-**

អនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងស្ដីពីការបង្កើតវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល ដែលបានចុះហត្ថលេខានៅទីក្រុងរីយ៉ូដឺហ្សានេរ៉ូ ប្រទេសប្រេស៊ីល នាថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១២

នស/រកម.១២១២.០១០២

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**ហត្ថលេខា**

**ម៉ុក ម៉ារេត**

លេខ ១០៥៤ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១២

**អគ្គលេខាធិការរងទីស្ដីការគណៈរដ្ឋមន្ត្រី [illegible] រាជរដ្ឋាភិបាល**

**ជ័យ សុខា**

2/24

# កិច្ចព្រមព្រៀងស្តីពីការបង្កើតវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល

ភាគីនៃកិច្ចព្រមព្រៀង៖

- ដោយទទួលស្គាល់ថាសមាហរណកម្មនៃកំណើនសេដ្ឋកិច្ច និងនិរន្តរភាពបរិស្ថាន មានសារៈសំខាន់ជាសារវន្ត សម្រាប់អនាគតនៃមនុស្សជាតិ។
- ដោយទទួលស្គាល់អំពីតម្រូវការចាំបាច់ដើម្បីអភិវឌ្ឍន៍ និងផ្សព្វផ្សាយគំរូថ្មីមួយនៃកំណើនសេដ្ឋកិច្ចពោលគឺ ការអភិវឌ្ឍបៃតង ដែលផ្តោតក្នុងពេលជាមួយគ្នាទៅលើការរីកចម្រើននៃសេដ្ឋកិច្ច និងនិរន្តរភាពបរិស្ថាន ដែល នៅទីបំផុត អាចទ្រទ្រង់ឲ្យមានគំរូថ្មីមួយជាសកល សម្រាប់និរន្តរភាពសេដ្ឋកិច្ច។
- ដោយគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព នៃប្រទេសកំពុងអភិវឌ្ឍ និងប្រទេសដែលមានសេដ្ឋកិច្ចលូតលាស់ហ័ស រួមទាំងសហគមន៍ក្រីក្រជាងគេនៅក្នុងប្រទេសទាំងនោះ និងប្រទេសដែលមានការអភិវឌ្ឍតិចតួច តាមរយៈ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍បៃតងប្រកបដោយប្រសិទ្ធភាព សំដៅកាត់បន្ថយភាពក្រីក្រ បង្កើតការងារ និង ភាតរភាពសង្គម ប្រកបដោយចីរភាពបរិស្ថាន។
- ដោយប្តេជ្ញាសម្រេចឲ្យបាននូវការអភិវឌ្ឍដោយចីរភាពនៅក្នុងសហគមន៍អន្តរជាតិ តាមរយៈការពិភាក្សា ការផ្លាស់ ប្តូរបទពិសោធ និងកិច្ចសហប្រតិបត្តិការ រវាងប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍ ទាំងវិស័យសាធារណៈ និងឯកជន។
- ដោយបានរួមចំណែកដល់លទ្ធផលប្រកបដោយជោគជ័យនៃដំណើរការរបស់អង្គការសហប្រជាជាតិ ស្តីពីការ អភិវឌ្ឍដោយចីរភាព និងការសម្រេចបាននូវគោលដៅអន្តរជាតិផ្សេងទៀត ដែលរួមមានគោលដៅអភិវឌ្ឍន៍ សហស្សវត្សរ៍គឺការលុបបំបាត់ភាពក្រីក្រនិងភាពអត់ឃ្លានធ្ងន់ធ្ងរ ការធានាចីរភាពបរិស្ថាន និងការបង្កើតភាពជាដៃ គូអភិវឌ្ឍលើពិភពលោក។
- ដោយមានកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយអង្គការអន្តរជាតិផ្សេងទៀត និងគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ ដើម្បី លើកកម្ពស់ការអភិវឌ្ឍបៃតង។
- ដោយយល់ឃើញថាការរៀបចំ និងការសម្រេចឲ្យបានការអភិវឌ្ឍបៃតងគឺទាមទារឲ្យមាននិរន្តរភាព និងទស្សនវិស័យ សម្រាប់រយៈពេលវែង។
- ដោយយល់ឃើញថា ដើម្បីដោះស្រាយការបម្រែបម្រួលអាកាសធាតុ និងអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍កាត់បន្ថយកាបូន ទាបប្រកបដោយប្រសិទ្ធភាព ទាមទារឲ្យមានអង្គការអន្តរជាតិជំនាញពហុវិស័យថ្មីមួយ ដែលមានការចូលរួមពី ភាគីពាក់ព័ន្ធ និង
- ដោយមានគោលបំណងបង្កើតវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកលជាអង្គការអន្តរជាតិ

បានឯកភាព ដូចតទៅ៖

## មាត្រា ១
## ការបង្កើត

១. ត្រូវបានបង្កើតវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល ដែលសរសេរកាត់ថា "វ.អ.ប.ស." ជាអង្គការអន្តរជាតិ។

២. វ.អ.ប.ស. មានទីស្នាក់ការកណ្តាលនៅក្នុងទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ។

## មាត្រា ២
## គោលបំណង

វ.អ.ប.ស. មានគោលបំណងលើកកម្ពស់ការអភិវឌ្ឍដោយចីរភាពក្នុងប្រទេសកំពុងអភិវឌ្ឍ ប្រទេសដែលមានសេដ្ឋកិច្ចលូតលាស់រហ័ស និងប្រទេសដែលមានការអភិវឌ្ឍតិចតួច ដោយត្រូវ ៖

ក. គាំទ្រ និងផ្សព្វផ្សាយគំរូថ្មីមួយនៃកំណើនសេដ្ឋកិច្ចតាមបែបការអភិវឌ្ឍបៃតង សំដៅដល់កំណើនសេដ្ឋកិច្ចដោយមានតុល្យភាពទៅនឹងនិរន្តរភាពបរិស្ថាន។

ខ. សម្រេចឲ្យបាននូវគោលដៅសំខាន់ៗមាន ការអភិវឌ្ឍសេដ្ឋកិច្ចនិងភាពធន់ទ្រាំ ការកាត់បន្ថយភាពក្រីក្រ ការបង្កើតការងារ និងភាពភាពសង្គម និងគោលដៅនិរន្តរភាពបរិស្ថាន ដូចជាការកាត់បន្ថយនិងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការអភិរក្សជីវៈចម្រុះ និងធានាសិទ្ធិទទួលបានថាមពលស្អាត ទឹកស្អាត និងដីធ្លី តាមតម្លៃសមស្រប និង

ឃ.បង្កើត និងកែលម្អលក្ខខណ្ឌសេដ្ឋកិច្ច បរិស្ថាន និងសង្គម នៃប្រទេសកំពុងអភិវឌ្ឍ និងប្រទេសដែលមានសេដ្ឋកិច្ចលូតលាស់រហ័សតាមរយៈការសហការភាពជាដៃគូរវាងប្រទេសជឿនលឿននិងប្រទេសកំពុងអភិវឌ្ឍ ទាំងវិស័យសាធារណៈនិងឯកជន។

## មាត្រា ៣
## និយមន័យ

សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ ៖

ក. *សមាជិកឧបត្ថម្ភ* សំដៅដល់សមាជិកនៃ វ.អ.ប.ស. ដែលផ្តល់វិភាគទានហិរញ្ញវត្ថុសម្រាប់រយៈពេលជាច្រើនឆ្នាំទៅក្នុងមូលនិធិស្នូល ក្នុងចំនួនមិនតិចជាង១៥លានដុល្លារអាមេរិកនៅក្នុងរយៈពេលបីឆ្នាំ ឬ ១០លានដុល្លារអាមេរិកនៅក្នុងរយៈពេលពីរឆ្នាំដំបូង។ តាមរយៈមតិកុងសង់ស៊ីស សន្និបាតនៃភាគីសមាជិកត្រូវពិនិត្យឡើងវិញ និងអាចកែតម្រូវលើទំហំ និងប្រភេទនៃវិភាគទាន ដែលចាំបាច់សម្រាប់ចាត់ជាសមាជិកឧបត្ថម្ភ ដើម្បីអាចគាំទ្រជាបន្តបន្ទាប់ដល់ការអភិវឌ្ឍនៃ វ.អ.ប.ស.។

ខ. *សមាជិកចូលរួម* សំដៅដល់សមាជិកនៃ វ.អ.ប.ស. ដែលមិនមែនជាសមាជិកឧបត្ថម្ភនៅក្នុងវាក្យខណ្ឌ ក។

គ. *សមាជិកដែលមានវត្តមាន និងដែលមានសិទ្ធិបោះឆ្នោត* សំដៅដល់សមាជិកដែលមានវត្តមាន និងដែលមានសិទ្ធិបោះឆ្នោតគាំទ្រ ឬ ជំទាស់។ កូរ៉ុមសម្រាប់រាល់ការសម្រេចនៃសន្និបាត ឬក្រុមប្រឹក្សាត្រូវតែជាមតិភាគច្រើនធម្មតា នៃសមាជិកក្នុងអង្គភាពដែលពាក់ព័ន្ធ។ ដើម្បីឲ្យច្បាស់ ការគណនាកូរ៉ុមនៅក្នុងសម័យប្រជុំ

សន្និបាតលើកដំបូង ត្រូវមានរដ្ឋ និងអង្គការសមាហរណកម្មថ្នាក់តំបន់ដែលជាហត្ថលេខី ដូចមានចែងនៅក្នុងមាត្រា ៥.៣ និង

ឃ. *អង្គការ* សំដៅដល់អង្គភាពដែលត្រូវបានស្គាល់ជាវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល ដែលត្រូវបានបង្កើតឡើងជាអង្គការមិនស្វែងរកប្រាក់ចំណេញ នាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១០ នៅសាធារណរដ្ឋកូរ៉េ។

## មាត្រា ៤
## សកម្មភាព

ដើម្បីសម្រេចគោលបំណងរបស់ខ្លួន វ.អ.ប.ស. ត្រូវចូលរួមនៅក្នុងសកម្មភាពដូចតទៅនេះ៖

ក. គាំទ្រដល់ប្រទេសកំពុងអភិវឌ្ឍ និងប្រទេសដែលមានសេដ្ឋកិច្ចលូតលាស់ហ័ស លើការកសាងសមត្ថភាពក្នុងការកសាង និងអនុវត្តផែនការអភិវឌ្ឍន៍បៃតងនៅថ្នាក់ជាតិ ថ្នាក់ខេត្ត ឬថ្នាក់មូលដ្ឋាន ដើម្បីជំរុញការកាត់បន្ថយភាពក្រីក្រ ការបង្កើតការងារ និងភាតរភាពសង្គម។

ខ. ធ្វើការសិក្សាស្រាវជ្រាវដើម្បីអភិវឌ្ឍទ្រឹស្តី និងជម្រុញការអនុវត្តជាក់ស្តែងលើការអភិវឌ្ឍបៃតង ពិសេសផ្តែកលើបទពិសោធពីរដ្ឋាភិបាល និងឧស្សាហកម្មនានា។

គ. សម្របសម្រួលកិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈនិងឯកជន ដើម្បីពង្រឹងបរិយាកាសអំណោយផលសម្រាប់ការវិនិយោគលើប្រសិទ្ធភាពធនធាន ការច្នៃប្រឌិត ផលិតកម្ម និងការប្រើប្រាស់ និងការផ្សព្វផ្សាយបទពិសោធន៍ល្អៗ។

ឃ. ផ្សព្វផ្សាយចំណេះដឹងដែលផ្អែកលើភស្តុតាង និងពង្រឹងការយល់ដឹងជាសាធារណៈ អំពីការអភិវឌ្ឍបៃតង និងការអភិវឌ្ឍដោយចីរភាព និង

ង. អនុវត្តសកម្មភាពដទៃៗទៀតដែលពាក់ព័ន្ធជាមួយគោលដៅនានារបស់ វ.អ.ប.ស.។

## មាត្រា ៥
## សមាជិកភាព

១. រដ្ឋ ឬ អង្គការសមាហរណកម្មថ្នាក់តំបន់[1] អាចក្លាយជាសមាជិកនៃ វ.អ.ប.ស. តាមរយៈការចូលជាភាគីនៅក្នុងកិច្ចព្រមព្រៀងនេះ។ សមាជិកភាពនៃ វ.អ.ប.ស. បើកចំហសម្រាប់រដ្ឋនានាដែលជាសមាជិកអង្គការសហប្រជាជាតិ ឬ អង្គការសមាហរណកម្មថ្នាក់តំបន់ ដែលយល់ព្រមតាមគោលបំណងរបស់ វ.អ.ប.ស. ដូចមានចែងក្នុងមាត្រា ២។

២. គ្មានសមាជិកណាមួយត្រូវទទួលខុសត្រូវចំពោះសកម្មភាព ការលើកលែង ឬ កាតព្វកិច្ចណាមួយនៅក្នុង វ.អ.ប.ស. ដោយហេតុតែឋានៈ ឬ ការចូលរួមរបស់ខ្លួននៅក្នុង វ.អ.ប.ស. ឡើយ។

៣. រដ្ឋ និងអង្គការសមាហរណកម្មថ្នាក់តំបន់ដែលជាហត្ថលេខី ដែលមិនបានដាក់ជូនលិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ឬ អនុម័តយល់ព្រម ទៅអគ្គនាយក ឲ្យបានមុនពេលដែលកិច្ចព្រមព្រៀងនេះចូលជាធរ

[1] *អង្គការសមាហរណកម្មថ្នាក់តំបន់ សំដៅដល់ អង្គការណាមួយដែលមានសមាជិកជារដ្ឋអធិបតេយ្យនៅក្នុងតំបន់ណាមួយ ដែលបានទទួលសិទ្ធិពីរដ្ឋជាសមាជិក ពាក់ព័ន្ធនឹងកិច្ចការនានាដែលស្ថិតក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងនេះ។*

មាន មានសិទ្ធិដូចជាសមាជិកដទៃដែរ ដែលរួមមាន សិទ្ធិក្នុងការបោះឆ្នោត និងលទ្ធភាពឈរឈ្មោះបោះឆ្នោត នៅក្នុងសម័យប្រជុំសន្និបាតលើកដំបូង ព្រមទាំងការពាក់ព័ន្ធនៅក្នុងតំណែងក្នុងក្រុមប្រឹក្សា។ ដើម្បីឲ្យច្បាស់ វាក្យខណ្ឌនេះ មិនត្រូវអនុវត្តនៅក្នុងសម័យប្រជុំសន្និបាតបន្តបន្ទាប់ឡើយ។

៤. អង្គការសមាហរណកម្មថ្នាក់តំបន់ណាមួយដែលក្លាយជាភាគីនៅក្នុងកិច្ចព្រមព្រៀងនេះ ដោយពុំមានរដ្ឋសមាជិកណាមួយរបស់ខ្លួនជាភាគីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវតែជាប់កាតព្វកិច្ចទាំងអស់នៅក្រោមកិច្ចព្រមព្រៀង។ ក្នុងករណីដែលអង្គការបែបនេះ មានរដ្ឋជាសមាជិករបស់ខ្លួនជាភាគីនៅក្នុងកិច្ចព្រមព្រៀងនេះ អង្គការទាំងនោះ និងរដ្ឋជាសមាជិកនៃអង្គការនោះ ត្រូវធ្វើការសម្រេចអំពីការទទួលខុសត្រូវរបស់ខ្លួនលើការអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្រោមកិច្ចព្រមព្រៀងនេះ។ ការរៀបចំផ្សេងទៀតអំពីបែបបទនៃការប្រតិបត្តិនៃសមាជិកភាពរបស់អង្គការសមាហរណកម្មថ្នាក់តំបន់ត្រូវចរចាមុនពេលអង្គការទាំងនេះក្លាយជាសមាជិក ហើយត្រូវអនុម័តដោយសន្និបាតនៅពេលក្រោយ។

៥. នៅក្នុងលិខិតូបករណ៍របស់ខ្លួនស្តីពីការផ្តល់សច្ចាប័ន ការទទួលយក ការអនុម័តឯកភាព ឬ ការសុំចូលជាសមាជិកនៃអង្គការសមាហរណកម្មថ្នាក់តំបន់ ត្រូវប្រកាសអំពីវិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួន ដែលទាក់ទងនឹងកិច្ចការនានាដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ។ អង្គការទាំងនេះត្រូវតែជូនដំណឹងដល់ស្ថាប័នតម្កល់ឯកសារ ហើយស្ថាប័ននេះត្រូវតែជូនដំណឹងជាបន្តដល់ភាគីជាសមាជិកអំពីការកែប្រែណាមួយនៃសមត្ថកិច្ចរបស់អង្គការទាំងនោះ។

## មាត្រា ៦
## ស្ថាប័ននានា

១. រ.អ.ប.ស. មានស្ថាប័នចម្បងៗជាអាទិ៍ សន្និបាត ក្រុមប្រឹក្សា គណកម្មាធិការប្រឹក្សាយោបល់ និងលេខាធិការដ្ឋាន។

២. រ.អ.ប.ស. អាចបង្កើតការិយាល័យសាខា ឬអង្គភាពចំណុះផ្សេងទៀត ដោយសេចក្តីសម្រេចរបស់សន្និបាតតាមការចាំបាច់ ដើម្បីទ្រទ្រង់ដល់សកម្មភាពរបស់ខ្លួន។

## មាត្រា ៧
## សន្និបាត

១. សន្និបាត គឺជាស្ថាប័នកំពូលនៃ រ.អ.ប.ស. ដែលមានសមាសភាពមកពីសមាជិករបស់ខ្លួន។

២. សន្និបាតនេះត្រូវប្រជុំរៀងរាល់ពីរឆ្នាំម្តងនៅក្នុងសម័យប្រជុំសាមញ្ញ ឬតាមការសម្រេចរបស់សន្និបាត។ សម័យប្រជុំសន្និបាតវិសាមញ្ញ ត្រូវកោះប្រជុំបានតាមការផ្តួចផ្តើមពីសមាជិករបស់ខ្លួនចំនួនមួយភាគបី។ សម័យប្រជុំសន្និបាតនានា ត្រូវប្រព្រឹត្តទៅនៅទីស្នាក់ការកណ្តាលនៃរ.អ.ប.ស. លើកលែងតែមានការសម្រេចរបស់សន្និបាតផ្ទុយពីនេះ។

៣. សន្និបាតនេះត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនដោយកុងសង់ស៊ីស នៅក្នុងសម័យប្រជុំលើកដំបូងរបស់ខ្លួន។ ដើម្បីឲ្យច្បាស់ បទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុងរបស់សន្និបាតមិនអាចមានខ្លឹមសារផ្ទុយពីកិច្ចព្រមព្រៀងបានឡើយ។

៤. សន្និបាតនេះអាចផ្តល់សិទ្ធិជាអ្នកសង្កេតការណ៍ដល់អង្គភាពដែលមិនមែនជារដ្ឋ ដូចជា អង្គការបរិស្ថាន ក្រុមហ៊ុនឯកជន វិទ្យាស្ថានស្រាវជ្រាវ និងអង្គការមិនមែនរដ្ឋាភិបាល ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានឯកភាពគ្នានៅក្នុងសន្និបាត។ អ្នកតំណាងដែលមានមុខងារជាអ្នកសង្កេតការណ៍ អាចចូលរួមក្នុងការពិភាក្សាក្នុងសន្និបាត ប៉ុន្តែ

ពុំមានសិទ្ធិបោះឆ្នោតនៅក្នុងសន្និបាតបានទេ។ មាត្រាដទៃទៀតដែលទាក់ទងនឹងការចូលរួមរបស់អ្នកសង្កេតការណ៍ក្នុងសន្និបាតនេះ អាចមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុង ដូចមានចែងនៅក្នុងវាក្យខណ្ឌទី ៣ នៃមាត្រា នេះ។

៥. សន្និបាតមានមុខងារ ដូចតទៅ៖

ក. បោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សា ដោយអនុលោមតាមមាត្រា ៨.២ និងពិនិត្យលើគោលការណ៍ប្តូរវេនសមាជិក

ខ. ជ្រើសតាំងអគ្គនាយក ដែលបានតែងតាំងដោយក្រុមប្រឹក្សា

គ. ពិនិត្យ និងអនុម័តលើសំណើវិសោធនកម្មកិច្ចព្រមព្រៀងនេះ ដោយអនុលោមតាមមាត្រា ២៤

ឃ.ណែនាំការអនុវត្តការងារទូទៅរបស់ វ.អ.ប.ស.

ង. ពិនិត្យមើលវឌ្ឍនភាពនៃការសម្រេចបាននូវគោលបំណងនានារបស់ វ.អ.ប.ស.

ច. ទទួលរបាយការណ៍ពីលេខាធិការដ្ឋានស្តីពីកិច្ចការយុទ្ធសាស្ត្រ ប្រតិបត្តិការ និងហិរញ្ញវត្ថុ និង

ឆ. ផ្តល់ការណែនាំអំពីភាពជាដៃគូសហប្រតិបត្តិការ និងការទំនាក់ទំនងជាមួយអង្គការអន្តរជាតិដទៃទៀត ដោយអនុលោមតាមមាត្រា១៦។

៦. សមាជិកមួយមានសិទ្ធិបោះឆ្នោតមួយសម្លេង។

៧. ទាក់ទងនឹងការកិច្ចទទួលខុសត្រូវរបស់ខ្លួនដោយអនុលោមតាមមាត្រា ៥.៤ និង ៥.៥ សមាជិកនានាដែលជាអង្គការសមាហរណកម្មថ្នាក់តំបន់មានសិទ្ធិបោះឆ្នោត ដោយមានចំនួនសម្លេងឆ្នោតស្មើនឹងចំនួនរដ្ឋជាសមាជិករបស់អង្គការ ដែលជារដ្ឋហត្ថលេខីនៅក្នុងកិច្ចព្រមព្រៀងនេះ។ បែបបទនៃការអនុវត្តសិទ្ធិជាសមាជិករបស់អង្គការសមាហរណកម្មថ្នាក់តំបន់ ត្រូវរៀបចំដាច់ដោយឡែកដូចមានចែងក្នុងមាត្រា ៥.៤ ដែលត្រូវបានចរចាមុនពេលអង្គការទាំងនេះចូលជាសមាជិក ។

៨. សន្និបាតត្រូវធ្វើសេចក្តីសម្រេចផ្អែកលើគោលការណ៍កុងសង់ស៊ីស។ ប្រសិនបើបានប្រឹងប្រែងអស់លទ្ធភាព ប៉ុន្តែនៅតែមិនអាចសម្រេចបានមតិកុងសង់ស៊ីសទេ ប្រធានអាចលើកសំណើឲ្យមានការសម្រេចជាជម្រើសចុងក្រោយតាមមតិភាគច្រើននៃចំនួនសមាជិកដែលមានវត្តមាននិងដែលមានសិទ្ធិបោះឆ្នោត លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ។ លើសពីនេះ ការសម្រេចនានាត្រូវតែធ្វើឡើងដោយសមាជិកឧបត្ថម្ភភាគច្រើន ដែលមានវត្តមាននិងដែលមានសិទ្ធិបោះឆ្នោត ក៏ដូចជាសមាជិកចូលរួមភាគច្រើនដែលមានវត្តមាននិងដែលមានសិទ្ធិបោះឆ្នោតផងដែរ។ ដើម្បីឲ្យច្បាស់ ការសម្រេចនានាត្រូវធ្វើឡើងទៅតាមនីតិវិធីដែលមានចែងជាលាយលក្ខអក្សរនៅក្នុងកិច្ចប្រជុំនានានៃសន្និបាត។

៩. សន្និបាតត្រូវបោះឆ្នោតជ្រើសតាំងប្រធានមួយរូប និងអនុប្រធានពីររូប ដែលមានអាណត្តិរយៈពេលពីរឆ្នាំ។

១០.ប្រធានដោយមានការគាំទ្រពីអនុប្រធាន ត្រូវធ្វើជាអធិបតីនៅក្នុងសន្និបាត និងត្រូវអនុវត្តការកិច្ចនានាដែលសន្និបាតប្រគល់ជូន។

១១. ប្រធានត្រូវទទួលខុសត្រូវនៅចំពោះមុខសន្និបាត នៅក្នុងសម័យប្រជុំសន្និបាត។

## មាត្រា ៨
## ក្រុមប្រឹក្សា

១. ក្រុមប្រឹក្សាត្រូវមានតួនាទីជាអង្គការនីតិប្រតិបត្តិរបស់ វ.អ.ប.ស. និងត្រូវទទួលខុសត្រូវដឹកនាំការងារនានារបស់ វ.អ.ប.ស. តាមការណែនាំរបស់សន្និបាត។

២. ក្រុមប្រឹក្សានេះត្រូវមានសមាជិកចំនួនមិនលើសពីដប់ប្រាំពីររូប ដូចខាងក្រោមនេះ៖

ក. សមាជិកឧបត្ថម្ភ ចំនួនប្រាំរូប ដែលបានជ្រើសតាំងដោយសន្និបាត

ខ. សមាជិកចូលរួម ចំនួនប្រាំរូប ដែលបានជ្រើសតាំងដោយសន្និបាត

គ. អ្នកជំនាញការ ឬ ភាគីមិនមែនរដ្ឋ ចំនួនប្រាំរូប ដែលអាចរួមចំណែកយ៉ាងច្រើនក្នុងការសម្រេចគោលបំណងរបស់វ.អ.ប.ស. ត្រូវតែងតាំងដោយក្រុមប្រឹក្សា

ឃ.ប្រទេសជាម្ចាស់ផ្ទះ ត្រូវមានអាសនៈអចិន្ត្រៃយ៍នៅក្នុងក្រុមប្រឹក្សានេះ និង

ង. អគ្គនាយកពុំមានសិទ្ធិបោះឆ្នោតទេ។

៣. សមាជិកក្រុមប្រឹក្សា ដូចមានចែងក្នុងវាក្យខណ្ឌ២ក, ខ និងគ ត្រូវមានអាណត្តិសម្រាប់រយៈពេលពីរឆ្នាំ លើកលែងតែករណីដូចមានចែងក្នុងវាក្យខណ្ឌ ៤។

៤. សន្និបាតត្រូវតែធានាថា ប្រមាណពាក់កណ្តាលនៃចំនួនសមាជិកដំបូងក្នុងក្រុមប្រឹក្សាដែលត្រូវជ្រើសតាំង ដូចមានចែងក្នុងវាក្យខណ្ឌ២ក, ខ និង គ ខាងលើ ត្រូវបានជាប់ឆ្នោតសម្រាប់អាណត្តិដំបូងដែលមានរយៈពេលមួយឆ្នាំ ដើម្បីអាចបន្តនិរន្តរភាពនៃសមាជិកភាពរបស់ក្រុមប្រឹក្សានេះ។

៥. តាមការណែនាំរបស់សន្និបាត ក្រុមប្រឹក្សានេះត្រូវមានមុខងារដូចតទៅ៖

ក. ជ្រើសរើសអគ្គនាយក សម្រាប់ការតែងតាំងដោយសន្និបាត

ខ. អនុម័តលើយុទ្ធសាស្ត្ររបស់ វ.អ.ប.ស. និងពិនិត្យឡើងវិញនូវលទ្ធផល ការតាមដាន និងវាយតម្លៃ

គ. អនុម័តលើកម្មវិធីការងារ និងថវិកាប្រចាំឆ្នាំ

ឃ. អនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច

ង. អនុម័តលើការទទួលយកថ្មីមួយចំនួនសម្រាប់គណកម្មាធិការប្រឹក្សាយោបល់ ដោយអនុលោមតាមមាត្រា៩.២

ច. អនុម័តលើលក្ខណវិនិច្ឆ័យសម្រាប់ជ្រើសរើសកម្មវិធីប្រចាំប្រទេស ដែលត្រូវតែមានសង្គតិភាពជាមួយគោលបំណងនានារបស់ វ.អ.ប.ស. និងផ្អែកលើលក្ខណវិនិច្ឆ័យអំពីគោលបំណងផ្សេងទៀត

ឆ. អនុម័តលើសមាជិកភាពរបស់អនុគណៈកម្មការរបស់ក្រុមប្រឹក្សា និង

ជ. អនុវត្តមុខងារដទៃទៀតដែលសន្និបាតប្រគល់ជូន ឬ ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ។

៦. សមាជិកនីមួយៗនៃក្រុមប្រឹក្សា ត្រូវមានសិទ្ធិបោះឆ្នោតមួយសម្លេង លើកលែងតែអគ្គនាយក។

៧. ក្រុមប្រឹក្សាត្រូវព្យាយាមធ្វើការសម្រេចផ្អែកលើគោលការណ៍កុងសង់ស៊ីសដោយប្រឹងប្រែងឲ្យអស់ពីលទ្ធភាព។ ប្រសិនបើបានប្រឹងប្រែងអស់លទ្ធភាព ប៉ុន្តែនៅតែមិនអាចឈានដល់មតិកុងសង់ស៊ីសទៀតនោះ ប្រធានអាចលើកសំណើឲ្យមានការសម្រេចជាជម្រើសចុងក្រោយតាមមតិភាគច្រើនធម្មតា នៃចំនួនសមាជិកដែលមានវត្តមាន និងដែលមានសិទ្ធិបោះឆ្នោត លើកលែងតែមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ។ លើសពីនេះ ការអនុម័តលើការសម្រេចនានា ត្រូវតែធ្វើឡើងដោយសមាជិកឧបត្ថម្ភភាគច្រើនដែលមានវត្តមាន និងដែលមានសិទ្ធិបោះឆ្នោត ក៏ដូចជា សមាជិកចូលរួមភាគច្រើនដែលមានវត្តមាន និងដែលមានសិទ្ធិបោះឆ្នោត។ ដើម្បីឲ្យច្បាស់ ការសម្រេចនានាត្រូវធ្វើឡើងតាមនីតិវិធីដែលមានចែងជាលាយលក្សអក្សរនៅចន្លោះកិច្ចប្រជុំនានានៃក្រុមប្រឹក្សានេះ។

៨. ក្រុមប្រឹក្សានេះត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន តាមមតិកុងសង់ស៊ីសក្នុងសម័យប្រជុំលើកដំបូងរបស់ខ្លួន។

៩. ក្រុមប្រឹក្សាត្រូវបោះឆ្នោតជ្រើសរើសប្រធានមួយរូប និងអនុប្រធានពីររូប ដែលមានអាណត្តិរយៈពេលពីរឆ្នាំ។

១០. ប្រធាន ដោយមានការគាំទ្រពីអនុប្រធាន ត្រូវធ្វើជាអធិបតីនៃក្រុមប្រឹក្សា និងត្រូវអនុវត្តមុខងារដែលបាន ប្រគល់ជូន។

១១. ប្រធានត្រូវទទួលខុសត្រូវនៅចំពោះមុខក្រុមប្រឹក្សា នៅក្នុងសម័យប្រជុំរបស់ខ្លួន។

១២. ដើម្បីឲ្យការសម្របសម្រួល និងប្រតិបត្តិការមានប្រសិទ្ធភាព ក្រុមប្រឹក្សាអាចបង្កើតអនុគណៈកម្មាធិការនានាទៅតាមការចាំបាច់ រួមមានអនុគណៈកម្មាធិការសម្របសម្រួល អនុគណៈកម្មាធិការធនធានមនុស្ស អនុគណៈកម្មាធិការកម្មវិធី និងអនុគណៈកម្មាធិការសវនកម្មនិងហិរញ្ញវត្ថុ។ អនុគណៈកម្មាធិការសវនកម្មនិងហិរញ្ញវត្ថុត្រូវមានសមាជិកឧបត្ថម្ភ ធ្វើជាប្រធាន។

## មាត្រា ៩
## គណកម្មាធិការប្រឹក្សាយោបល់

១. ក្នុងនាមជាស្ថាប័នពិគ្រោះយោបល់ និងផ្តល់យោបល់គណកម្មាធិការប្រឹក្សាយោបល់ ត្រូវមានតួនាទីដូចតទៅ៖

ក. ធ្វើជាវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈនិងឯកជន ស្តីពីការអភិវឌ្ឍបៃតង និង

ខ. ផ្តល់យោបល់ដល់ក្រុមប្រឹក្សាអំពីយុទ្ធសាស្ត្រ និងសកម្មភាពនានារបស់ វ.អ.ប.ស. រួមមានកត្តាបង្រួបបង្រួម និងទំនាក់ទំនងរវាង វ.អ.ប.ស. និងអង្គការ ស្ថាប័នពាក់ព័ន្ធដទៃទៀត ដូចមានចែងនៅក្នុងមាត្រា១៦។

២. គណៈកម្មាធិការប្រឹក្សាយោបល់ត្រូវមានសមាសភាពជាអ្នកជំនាញការ និងភាគីដែលមិនមែនជារដ្ឋក្នុងនាមជាអ្នកនាំមុខ។ ពាក្យសុំចូលជាសមាជិកនៅក្នុងគណៈកម្មាធិការប្រឹក្សាយោបល់ត្រូវដាក់ជូនទៅអគ្គនាយកជាលាយលក្សណ៍អក្សរ និងត្រូវមានការអនុម័តពីក្រុមប្រឹក្សា ដោយអនុលោមតាមមាត្រា ៨.៥ង។

៣. គណៈកម្មាធិការប្រឹក្សាយោបល់ត្រូវប្រជុំនៅក្នុងសម័យប្រជុំសាមញ្ញប្រចាំឆ្នាំ លើកលែងតែមានការសម្រេចផ្សេងទៀត។

៤. គណៈកម្មាធិការប្រឹក្សាយោបល់ត្រូវអនុម័តលើបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន និងអាចបោះឆ្នោតជ្រើសរើសប្រធានមួយរូប និងអនុប្រធានមួយរូប។

## មាត្រា ១០
## លេខាធិការដ្ឋាន និងអគ្គនាយក

១. តាមការណែនាំរបស់ក្រុមប្រឹក្សា និងសន្និបាត លេខាធិការដ្ឋានមានតួនាទីជាអង្គភាពប្រតិបត្តិការដ៏សំខាន់នៃ វ.អ.ប.ស. និងស្ថិតក្រោមការដឹកនាំរបស់អគ្គនាយកមួយរូប។

២. អគ្គនាយកត្រូវជ្រើសរើសដោយក្រុមប្រឹក្សា និងតែងតាំងដោយសន្និបាត។ អគ្គនាយកអាចចូលរួមនៅក្នុងកិច្ចប្រជុំនានានៃក្រុមប្រឹក្សា និងសន្និបាត ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតនៅក្នុងកិច្ចប្រជុំទាំងនេះទេ។

៣. អគ្គនាយកនឹងត្រូវតែងតាំងសម្រាប់អាណត្តិដំបូងដែលមានរយៈពេលបួនឆ្នាំ និងអាចតែងតាំងឡើងវិញសម្រាប់មួយអាណត្តិជាបន្ថែមទៀត។

៤. បន្ថែមលើមុខងារនានារបស់ខ្លួន ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ឬ ដែលក្រុមប្រឹក្សា ឬ សន្និបាតប្រគល់ជូននៅក្នុងពេលណាមួយ និងតាមការណែនាំរបស់ក្រុមប្រឹក្សា និងសន្និបាត អគ្គនាយកត្រូវ ៖

ក. ផ្តល់ការដឹកនាំជាយុទ្ធសាស្ត្រសម្រាប់ វ.អ.ប.ស.

ខ. រៀបចំឯកសារចាំបាច់អំពីប្រតិបត្តិការ និងហិរញ្ញវត្ថុ

គ. រាយការណ៍ស្តីពីការអនុវត្តជារួមនៃសកម្មភាពរបស់ វ.អ.ប.ស. និងទាក់ទាញការយកចិត្តទុកដាក់ពីក្រុមប្រឹក្សាលើរាល់កិច្ចការ ដែលអគ្គនាយកចាត់ទុកថាអាចមានឥទ្ធិពលមកលើការបំពេញគោលបំណងរបស់ វ.អ.ប.ស.

ឃ.អនុវត្តតាមការណែនាំរបស់សន្និបាត និងក្រុមប្រឹក្សា និង

ង. ជាតំណាង វ.អ.ប.ស.ក្នុងមជ្ឈដ្ឋានខាងក្រៅ និងបង្កើតទំនាក់ទំនងរឹងមាំជាមួយសមាជិកនិងអ្នកពាក់ព័ន្ធនានា។

៥. លេខាធិការដ្ឋាន ត្រូវទទួលខុសត្រូវចំពោះមុខអគ្គនាយក និងត្រូវគាំទ្រដល់អគ្គនាយកក្នុងការអនុវត្តមុខងារដែលមានចែងក្នុងវាក្យខណ្ឌ ៤ និងសកម្មភាពស្នូលរបស់ វ.អ.ប.ស.។

៦. នៅក្នុងការអនុវត្តមុខងាររបស់ខ្លួន អគ្គនាយក និងបុគ្គលិកលេខាធិការដ្ឋាន មិនត្រូវស្វែងរក និងទទួលយកការណែនាំពីរដ្ឋណាមួយ ឬ អាជ្ញាធរណាមួយនៅខាងក្រៅ វ.អ.ប.ស. ឡើយ។ ពួកគេមិនត្រូវអនុវត្តសកម្មភាពណាមួយដែលអាចមានឥទ្ធិពលអវិជ្ជមានមកលើភារកិច្ចរបស់ខ្លួន ក្នុងនាមជាមន្ត្រីអន្តរជាតិឡើយ។

៧. អគ្គនាយកត្រូវតែងតាំងបុគ្គលិកអគ្គលេខាធិការ អនុលោមតាមបទប្បញ្ញត្តិស្តីពីការជ្រើសរើសបុគ្គលិក ដែលអនុម័តដោយក្រុមប្រឹក្សា។ នៅក្នុងការជ្រើសរើស និងការចាត់តាំងបុគ្គលិក ត្រូវគិតគូរជាចាំបាច់អំពីប្រសិទ្ធភាព សមត្ថភាព ស្នាដៃ និងស្មារតីបង្រួបបង្រួម ដោយពិចារណាអំពីគោលការណ៍សមភាពយេនឌ័រ។

## មាត្រា ១១
## ការប្រើភាសា

ការប្រើភាសារបស់ វ.អ.ប.ស. គឺយកភាសាអង់គ្លេស។

## មាត្រា ១២
## ហិរញ្ញវត្ថុ

១. វ.អ.ប.ស. ទទួលធនធានហិរញ្ញវត្ថុរបស់ខ្លួនតាមរយៈ៖

ក. វិភាគទានស្ម័គ្រចិត្តដែលសមាជិកផ្តល់ជូន

ខ. វិភាគទានស្ម័គ្រចិត្តផ្តល់ជូនដោយប្រភពមិនមែនរដ្ឋាភិបាល

គ. ការលក់ឯកសារ និងប្រាក់ចំណូលផ្សេងទៀត

ឃ. ប្រាក់ចំណូលបានពីការប្រាក់ដែលមានពីមូលនិធិដែលមានគណនេយ្យភាពពេញលេញ និង

ង. ប្រភពនានាផ្សេងទៀត អនុលោមតាមបទបញ្ញាហិរញ្ញវត្ថុ ដែលត្រូវអនុម័តដោយសន្និបាត តាមមតិកុងសង់ស៊ីស។

២. សមាជិកទទួលការលើកទឹកចិត្តដើម្បីផ្តល់ការគាំទ្រដល់ វ.អ.ប.ស. និងធានាឲ្យមានស្ថិរភាពហិរញ្ញវត្ថុ តាមរយៈវិភាគទានស្ម័គ្រចិត្តប្រចាំឆ្នាំទៅក្នុងមូលនិធិស្នូល ការចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពនានារបស់វិទ្យាស្ថាននេះ ឬ មធ្យោបាយសមស្របផ្សេងទៀត។

៣. ដើម្បីលើកកម្ពស់តម្លាភាពហិរញ្ញវត្ថុ សវនកម្មហិរញ្ញវត្ថុលើប្រតិបត្តិការរបស់ វ.អ.ប.ស. ត្រូវអនុវត្តនូវសវនកម្មជារៀងរាល់ឆ្នាំ ពីសវនករឯករាជ្យមកពីស្ថាប័នខាងក្រៅ ដែលតែងតាំងដោយក្រុមប្រឹក្សា ហើយសវនកម្មត្រូវធ្វើឡើងស្របតាមស្តង់ដាសវនកម្មអន្តរជាតិ។

៤. របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច ត្រូវផ្តល់ជូនដល់សមាជិកជាបន្ទាន់តាមតែអាចធ្វើទៅបាន នៅបំណាច់កាលបរិច្ឆេទនៃឆ្នាំហិរញ្ញវត្ថុនីមួយៗ ប៉ុន្តែមិនឲ្យយឺតជាងប្រាំមួយខែ ក្រោយកាលបរិច្ឆេទនោះ និងត្រូវសុំការអនុម័តពីក្រុមប្រឹក្សានៅក្នុងសម័យប្រជុំនាពេលខាងមុខ ទៅតាមពេលវេលាសមស្រប។

## មាត្រា ១៣
## ការផ្សព្វផ្សាយ

ស្ថាប័ននានាចំណុះ វ.អ.ប.ស. ត្រូវរៀបចំគោលនយោបាយទូលំទូលាយអំពីការផ្សព្វផ្សាយ ដែលធានាឲ្យមានតម្លាភាពនៃការងាររបស់ វ.អ.ប.ស. មានជាអាទិ៍៖

ក. ការពិភាក្សា សេចក្តីសម្រេចនានា និងឯកសារត្រូវបានទទួល បានពិនិត្យ និងអនុម័តដោយសន្និបាត

ខ. លក្ខណៈវិនិច្ឆ័យដែលជាមូលដ្ឋានសម្រាប់ការផ្តល់ឲ្យអង្គភាពនានានូវឋានានុក្រមជាអ្នកសង្កេតការណ៍

គ. ការពិភាក្សា សេចក្តីសម្រេច និងឯកសារពាក់ព័ន្ធនានានៅក្នុងក្រុមប្រឹក្សានេះ

ឃ. លក្ខណវិនិច្ឆ័យ សម្រាប់ការជ្រើសរើសអ្នកជំនាញការ និងភាគីមិនមែនរដ្ឋ នៅក្នុងក្រុមប្រឹក្សា

ង. លក្ខណវិនិច្ឆ័យ និងវិធីសាស្ត្រសម្រាប់សកម្មភាពនៃកម្មវិធីប្រចាំប្រទេសនានា

ច. លក្ខណវិនិច្ឆ័យសម្រាប់ការអនុម័តឯកភាពលើសមាជិកគណកម្មាធិការប្រឹក្សាយោបល់ និង

ឆ. របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានធ្វើសវនកម្មរួចរបស់ វ.អ.ប.ស.។

## មាត្រា ១៤
## បុគ្គលភាពគតិយុត្ត

វ.អ.ប.ស. មានបុគ្គលលក្ខណៈគតិយុត្ត និងសមត្ថភាពដូចតទៅ៖

ក. ចុះកិច្ចសន្យា

ខ. ទិញ និងលក់អចលនទ្រព្យ និងចលនទ្រព្យ និង

គ. ចាត់ចែង និងការពារខ្លួនតាមនីតិវិធីច្បាប់។

## មាត្រា ១៥
## បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិ

វ.អ.ប.ស. មានបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិនៅក្នុងរដ្ឋជាសមាជិកដែលមានស្នាក់ការកណ្តាល និងអាចស្វែងរកបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិនៅក្នុងសមាជិកផ្សេងទៀត ដែលចាំបាច់ និងសមស្របសម្រាប់ការអនុវត្តមុខងាររបស់ វ.អ.ប.ស. នៅក្នុងដែនដីរបស់រដ្ឋជាសមាជិក ដោយគិតគូរសមស្របអំពីបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិបែបនេះ ដែលធ្លាប់មានប្រើប្រាស់នៅក្នុងអង្គការអន្តរជាតិប្រហាក់ប្រហែលគ្នានេះ។ បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិបែបនេះត្រូវបានកំណត់នៅក្នុងកិច្ចព្រមព្រៀងដោយឡែកក្នុងចំណោម ឬរវាង វ.អ.ប.ស. និងសមាជិកនីមួយៗ។

## មាត្រា ១៦
## ភាពជាដៃគូសហប្រតិបត្តិការ

១. វ.អ.ប.ស. អាចបង្កើតទំនាក់ទំនងសហប្រតិបត្តិការជាមួយអង្គការដទៃ ដែលរួមទាំង អង្គការអន្តរជាតិ អង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីសម្រេចបាននូវគោលបំណងរបស់ វ.អ.ប.ស.។

២. វ.អ.ប.ស. ក៏អាចអញ្ជើញអង្គការនានាដែលមានគោលបំណងប្រហែលគ្នាលើការអភិវឌ្ឍបៃតង ដើម្បីចូលរួមជាដៃគូយុទ្ធសាស្ត្រ សម្រាប់កិច្ចសហប្រតិបត្តិការជាមួយគ្នាទៅវិញទៅមកសម្រាប់រយៈពេលមធ្យម និងរយៈពេលវែងផងដែរ។

## មាត្រា ១៧
## អន្តរប្បញ្ញត្តិ

១. មុនពេលដែលលេខាធិការដ្ឋាននៃ វ.អ.ប.ស. បានបង្កើតឡើង អង្គការនេះត្រូវមានតួនាទី និងអនុវត្តមុខងារជាលេខាធិការដ្ឋាន។ នាយកប្រតិបត្តិនៃអង្គការនេះ ត្រូវមានតួនាទីជាអគ្គនាយកនៃ វ.អ.ប.ស. រហូតដល់ពេលដែលសន្និបាតបានតែងតាំងអគ្គនាយក អនុលោមតាមមាត្រា ៧.៥ខ។

២. នៅក្រោយពេលកិច្ចព្រមព្រៀងនេះចូលជាធរមានសិទ្ធិ កាតព្វកិច្ច ការសន្យានានា សាខា/ការិយាល័យតំបន់[2] ដែលមានស្រាប់ និងទ្រព្យរបស់អង្គការខាងលើ ត្រូវតែប្រគល់ទៅឲ្យ វ.អ.ប.ស. អនុលោមតាមដំណើរការចាំបាច់របស់អង្គភាពនោះ។

៣. បទបញ្ជា បទប្បញ្ញត្តិ សេចក្តីសម្រេច នីតិវិធី និងការអនុវត្តរបស់អង្គការនេះនឹងត្រូវ វ.អ.ប.ស. យកមកអនុវត្ត ហូតដល់មានការសម្រេចណាមួយរបស់សន្និបាត ក្រុមប្រឹក្សា ឬ អគ្គនាយកទៅតាមករណីសមស្រប លើកលែងតែការអនុវត្តទាំងនោះពុំមានសង្គតិភាពជាមួយកិច្ចព្រមព្រៀងនេះ ឬអាចធ្វើឡើងតាមរយៈបទបញ្ជា បទប្បញ្ញត្តិ សេចក្តីសម្រេច នីតិវិធី និងបទពិសោធ ដែលត្រូវបានអនុម័តដោយសន្និបាត ឬ ក្រុមប្រឹក្សា។

៤. លុះត្រាណារដ្ឋ និងអង្គការសមាហរណកម្មថ្នាក់តំបន់ដែលក្លាយជាសមាជិកនៃកិច្ចព្រមព្រៀងមានចំនួនគ្រប់គ្រាន់ ចំណុចនីមួយៗដែលមានចែងនៅក្នុងវាក្យខណ្ឌរងចាប់ពី ក ដល់ គ នៃមាត្រា ៨.២ ដែលជាតម្រូវការអំពីចំនួនសមាជិកក្រុមប្រឹក្សាអាចយកមកប្រើបាន ដោយគ្រាន់តែរក្សាភាពបត់បែនស្របតាមសេចក្តីសម្រេចរបស់សន្និបាត។

## មាត្រា ១៨
## ការិយាល័យតម្កល់ឯកសារ

អគ្គនាយកនៃលេខាធិការដ្ឋាន គឺជាអ្នករក្សាទុកកិច្ចព្រមព្រៀងនេះ។

## មាត្រា ១៩
## ហត្ថលេខា

កិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខានៅក្រុងរីយ៉ូ ដឺហ្សាណេរ៉ូ នៃប្រទេសប្រេស៊ីល កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០១២ និងត្រូវបើកចំហសម្រាប់ទទួលហត្ថលេខាសម្រាប់រយៈពេលដប់ពីរខែបន្តទៀត។

## មាត្រា ២០
## ការផ្តល់សច្ចាប័ន ការទទួលយក និងការអនុម័ត

១. រដ្ឋ និងអង្គការសមាហរណកម្មថ្នាក់តំបន់ដែលជាហត្ថលេខី ត្រូវផ្តល់សច្ចាប័ន ទទួលយក ឬ អនុម័តលើកិច្ចព្រមព្រៀងនេះ ។

២. លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក និងការអនុម័ត នឹងត្រូវតម្កល់ទុកនៅការិយាល័យតម្កល់ឯកសារ។

## មាត្រា ២១
## ការសុំចូលជាសមាជិក

[2] ទាក់ទងនឹងការប្រគល់អំណាចរបស់ការិយាល័យតំបន់នៃ វ.អ.ប.ស. ការពិគ្រោះយោបល់ជាមួយរដ្ឋាភិបាលប្រទេសដាណឺម៉ាក់ និងអារ៉ាប់រួម គឺជាការចាំបាច់។

១. កិច្ចព្រមព្រៀងនេះត្រូវបើកចំហសម្រាប់ការសុំចូលជាសមាជិកពីភាគីរដ្ឋ ឬអង្គការសមាហរណកម្មថ្នាក់តំបន់ណាមួយ ដែលពុំបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

២. លិខិតូបករណ៍នៃការសុំចូលជាសមាជិកត្រូវតម្កល់ទុកនៅការិយាល័យតម្កល់ឯកសារ។

## មាត្រា ២២
## ការចូលជាធរមាន

១. កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាននៅថ្ងៃទីសាមសិប បន្ទាប់ពីការតម្កល់ទុកនូវលិខិតូបករណ៍ទីបី សម្រាប់ការផ្តល់សច្ចាប័ន ការទទួលយក ការអនុម័តឯកភាព ឬការសុំចូលជាសមាជិក។

២. សម្រាប់រដ្ឋ ឬ អង្គការសមាហរណកម្មថ្នាក់តំបន់នីមួយៗ ដែលបានផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬ ការសុំចូលជាសមាជិក នៅក្រោយពេលដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន ការចូលជាធរមាននៅក្រោមកិច្ចព្រមព្រៀងនេះសម្រាប់ភាគីទាំងនោះ គឺនៅថ្ងៃទីសាមសិប បន្ទាប់ពីការតម្កល់នូវលិខិតូបករណ៍ដែលពាក់ព័ន្ធនោះ។

## មាត្រា ២៣
## លក្ខខណ្ឌលើកលែង

គ្មានលក្ខខណ្ឌលើកលែងណាមួយដែលមានចែងសម្រាប់កិច្ចព្រមព្រៀងនេះទេ។

## មាត្រា ២៤
## វិសោធនកម្ម

១. ភាគីណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ អាចលើកស្នើឲ្យមានវិសោធនកម្មលើកិច្ចព្រមព្រៀងនេះ ដោយត្រូវដាក់ជូនសំណើនោះទៅអគ្គនាយកនៃលេខាធិការដ្ឋាន។ អគ្គនាយកត្រូវជូនដំណឹងអំពីសំណើវិសោធនកម្មនោះទៅសមាជិកទាំងអស់នៃ វ.អ.ប.ស. យ៉ាងហោចណាស់កៅសិបថ្ងៃ មុនការពិចារណាដោយសន្និបាតលើសំណើនោះ។

២. វិសោធនកម្មកិច្ចព្រមព្រៀងនេះចូលជាធរមានចំពោះសមាជិកទាំងឡាយដែលបានទទួលយកវិសោធនកម្មកិច្ចព្រមព្រៀងរយៈពេលកៅសិបថ្ងៃ បន្ទាប់ពីការតម្កល់នូវលិខិតូបករណ៍យល់ព្រមដោយសមាជិកយ៉ាងហោចពីរភាគបីនៃកិច្ចព្រមព្រៀង ដែលអនុម័តចុងក្រោយដោយសន្និបាត លើកលែងមានបទប្បញ្ញត្តិដោយឡែកក្នុងសំណើសុំវិសោធនកម្ម។ លិខិតូបករណ៍ចាំបាច់ត្រូវមានសម្លេងពីរភាគបីនៃសមាជិកឧបត្ថម្ភ រួមទាំងសម្លេងពីរភាគបីនៃសមាជិកចូលរួម ទើបវិសោធនកម្មនេះចូលជាធរមាន។

## មាត្រា ២៥
## ការលាលែង

សមាជិកណាមួយអាចដកខ្លួនចេញពីកិច្ចព្រមព្រៀងនេះ ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីគោលបំណងក្នុងការដកខ្លួនចេញពីកិច្ចព្រមព្រៀងនេះ។ ការដកខ្លួនចេញនេះចូលជាធរមានក្នុងរយៈពេលប្រាំមួយខែ បន្ទាប់ពីកាល បរិច្ឆេទនៃការទទួលលិខិតជូនដំណឹង ដោយអគ្គនាយកនៃលេខាធិការដ្ឋាន។

## មាត្រា ២៦
## ការបកស្រាយ

ក្នុងករណីមានការបកស្រាយរវាងសមាជិកណាមួយ និង វ.អ.ប.ស. ឬរវាងសមាជិកណាមួយនៃ វ.អ.ប.ស. ត្រូវផ្ញើជូនប្រធានសន្និបាត ដើម្បីទទួលបានការសម្រេចដោយសន្និបាត។ សន្និបាតធ្វើសេចក្តីសម្រេចតាមមតិកុងសង់ស៊ីស។ ក្នុងករណីគេមតិកុងសង់ស៊ីសពុំបានទេ សេចក្តីសម្រេចត្រូវអនុម័តដោយសមាជិកពីរភាគបីដែលមានវត្តមាន និងដែលមានសិទ្ធិបោះឆ្នោត ជាជម្រើសចុងក្រោយ។ ការអនុម័តសេចក្តីសម្រេចខាងលើត្រូវមានសម្លេងពីរភាគបីនៃសមាជិក ឧបត្ថម្ភដែលមានវត្តមាន និងមានសិទ្ធិបោះឆ្នោត ព្រមទាំងសម្លេងពីរភាគបីនៃសមាជិកចូលរួមដែលមានវត្តមាននិង ដែលមានសិទ្ធិបោះឆ្នោត។ កិច្ចព្រមព្រៀងនេះ រួមទាំងសេចក្តីសម្រេចទាំងឡាយត្រូវបកស្រាយដោយអនុលោមតាមនីតិវិធីបកស្រាយទៅតាមវិធានទំនៀមទម្លាប់នៃនីតិសាធារណៈអន្តរជាតិ ដូចជាអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញាអនុម័តឆ្នាំ១៩៦៩។

## មាត្រា ២៧
## ការពិគ្រោះយោបល់

១. សមាជិកណាមួយរបស់ វ.អ.ប.ស. អាចស្នើសុំជាលាយលក្ខណ៍អក្សរដើម្បីពិគ្រោះយោបល់ជាមួយអគ្គនាយកនៃ វ.អ.ប.ស.ឬជាមួយសមាជិកដទៃទៀតអំពីបញ្ហាណាមួយទាក់ទងនឹងការអនុវត្ត ឬដំណើរការនៃកិច្ចព្រមព្រៀងនេះ។

២. ការពិគ្រោះយោបល់របស់សមាជិកត្រូវសម្រេចនូវដំណោះស្រាយបញ្ហាដែលមានការយោគយល់គ្នាទៅវិញទៅមកដោយសន្តិវិធី។

៣. ការពិគ្រោះយោបល់ក្នុងមាត្រានេះមិនត្រូវផ្សព្វផ្សាយដល់សមាជិកដទៃទៀតណាមួយ លុះត្រាតែមានការយល់ព្រមផ្សេង ដោយមិនប៉ះពាល់សិទ្ធិនៃសមាជិកណាមួយដែលបានលើកបញ្ហានៅក្នុងសន្និបាត។

## មាត្រា ២៨
## ការបញ្ចប់

១. កិច្ចព្រមព្រៀងនេះអាចបញ្ចប់បានតាមរយៈការសម្រេចដោយមតិកុងសង់ស៊ីសតែមួយគត់នៅក្នុងសន្និបាត ដែលមានសមាជិកទាំងអស់ចូលរួម។

២. រាល់សេចក្តីសម្រេចដែលធ្វើឡើងនៅក្នុងវាក្យខណ្ឌ ១ មិនត្រូវចូលជាធរមានមុនពេលផុតកំណត់ដប់ពីរខែឡើយ លើកលែងតែមានការសម្រេចដោយឡែករបស់សន្និបាត ដោយមតិកុងសង់ស៊ីស។

៣. ការបញ្ចប់កិច្ចព្រមព្រៀងនេះ នឹងពុំមានឥទ្ធិពលមកលើការអនុវត្តគម្រោង ឬកម្មវិធីណាមួយ ដែលធ្វើឡើងនៅក្រោមកិច្ចព្រមព្រៀងនេះ និងមិនប្រតិបត្តិពេញលេញនៅក្នុងពេលបិទបញ្ចប់កិច្ចព្រមព្រៀងនេះឡើយ លើកលែងតែមានការឯកភាពជាឯកច្ឆន្ទពីសន្និបាត។

៤. ក្រោយការបញ្ចប់ សន្និបាតអាចមូលមតិកុងសង់ស៊ីសក្នុងការផ្ទេរទ្រព្យ និងសម្បត្តិនានារបស់ វ.អ.ប.ស. ទៅអង្គការអន្តរជាតិមួយ ឬ ច្រើន ដែលមានគោលដៅដូចគ្នា ឬ គោលដៅដូចគ្នាភាគច្រើន ទៅនឹងគោលដៅរបស់

វ.អ.ប.ស. ដូចមានចែងក្នុងមាត្រា ២។ ផ្ទុយទៅវិញ ទ្រព្យនិងសម្បត្តិរបស់ វ.អ.ប.ស. អាចបែងចែកទៅសមាជិកនានា ដោយអនុលោមតាមនីតិវិធីណាមួយដែលបានឯកភាពដោយសន្និបាត។

ដើម្បីជាសាក្សី តំណាងដូចមានឈ្មោះខាងក្រោម ដែលបានទទួលសិទ្ធិពីរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

ធ្វើជាកាសាអង់គ្លេស នៅទីក្រុងវីយ៉ូ ដឺ ហ្សានេរ៉ូ នាថ្ងៃទីម្ភៃ ខែមិថុនា ឆ្នាំពីរពាន់ដប់ពីរ ។

រដ្ឋាភិបាលអូស្ត្រាលី

ព្រះរាជាណាចក្រកម្ពុជា

សាធារណរដ្ឋកូស្តារីកា

ព្រះរាជាណាចក្រដាណឺម៉ាក់

សាធារណរដ្ឋប្រជាធិបតេយ្យសហព័ន្ធអេត្យូពី

សាធារណរដ្ឋហ្គុយយ៉ាណា

សាធារណរដ្ឋកូរ៉េ

អារ៉ាប់រួម

សាធារណរដ្ឋគីរីបាទី

ចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង

ព្រះរាជាណាចក្រនរវេស

សាធារណរដ្ឋសង្គមនិយមវៀតណាម

រដ្ឋឯករាជ្យប៉ាពួញូហ្គីនេ

សាធារណរដ្ឋហ្វីលីពីន

សាធារណរដ្ឋប៉ារ៉ាហ្គាយ

កាលបរិច្ឆេទៈ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១

រដ្ឋកាតា

## Agreement on the Establishment of the Global Green Growth Institute

The Parties to this Agreement,

Acknowledging that the integration of economic growth and environmental sustainability is essential for the future of humankind;

Recognizing the need to develop and diffuse a new model of economic growth—green growth—that simultaneously targets economic performance and environmental sustainability, ultimately supporting the global paradigm shift towards a sustainable economy;

Supporting the sustainable development of developing and emerging countries, including the poorest communities within those countries and the least developed countries, through effective green growth strategies and plans that deliver poverty reduction, job creation and social inclusion in an environmentally sustainable manner;

Striving to achieve the sustainable development of the international community through dialogue, collective learning and collaboration between developed and developing countries and the public and private sectors;

Contributing to the successful outcome of the United Nations process on sustainable development and attainment of other internationally agreed goals, including the Millennium Development Goals such as eradicating extreme poverty and hunger, ensuring environmental sustainability and developing global partnerships for development;

Pursuing a close collaboration with other international organizations and international financial institutions that promote green growth;

Understanding that the design and implementation of green growth require continuity and a long term perspective;

Noting that a new kind of interdisciplinary and multi-stakeholder international organization is necessary to effectively address climate change and implement low-carbon development strategies; and

Desiring to establish the Global Green Growth Institute as an international organization;

Have agreed as follows:

## Article 1
## ESTABLISHMENT

1. The Global Green Growth Institute is hereby established as an international organization (hereinafter referred to as the "GGGI").

2. The headquarters of the GGGI shall be located in Seoul, the Republic of Korea.

## Article 2
## OBJECTIVES

The GGGI shall promote sustainable development of developing and emerging countries, including the least developed countries, by:

a. supporting and diffusing a new paradigm of economic growth: green growth, which is a balanced advance of economic growth and environmental sustainability;

b. targeting key aspects of economic performance and resilience, poverty reduction, job creation and social inclusion, and those of environmental sustainability such as climate change mitigation and adaptation, biodiversity protection and securing access to affordable, clean energy, clean water and land; and

c. creating and improving the economic, environmental and social conditions of developing and emerging countries through partnerships between developed and developing countries and the public and private sectors.

## Article 3
## DEFINITIONS

For the purposes of this Agreement:

a. *contributing member* means a Member of the GGGI that has provided a multi-year financial contribution of core funding of no less than 15 million USD over three years or 10 million USD over the first two years. The level and nature of contribution required to qualify as a contributing member shall be kept under review by the Assembly, and may be adjusted by the Assembly by consensus to support the growth of the GGGI over time;

b. *participating member* means a Member of the GGGI that is not a contributing member under paragraph a;

c. *members present and voting* means members present and casting an affirmative or a negative vote. A quorum for any decision of the Assembly or Council shall be a simple majority of the

members of the respective organ. For the avoidance of doubt, signatory States and regional integration organizations under Article 5.3 shall be counted for the purposes of quorum at the first session of the Assembly; and

d. *the Organization* means the body known as the Global Green Growth Institute established as a non-profit foundation on 16 June 2010 in the Republic of Korea.

**Article 4**

**ACTIVITIES**

In order to accomplish its objectives, the GGGI shall engage in the following types of activities:

a. supporting developing and emerging countries with capacity building to design and implement green growth plans at the national, provincial, or local level to facilitate poverty reduction, job creation and social inclusion;

b. pursuing research to advance the theory and practice of green growth, drawing particularly from the experience of governments and industries;

c. facilitating public-private cooperation to foster an enabling environment for resource-efficient investment, innovation, production and consumption, and diffusion of best practices;

d. disseminating evidence-based knowledge and enhancing public awareness of green growth and sustainable development; and

e. performing any other activities relevant to the objectives of the GGGI.

**Article 5**

**MEMBERSHIP**

1. A state or regional integration organization[1] shall become a Member of the GGGI by becoming Party to this Agreement. The membership of the GGGI is open to any member state of the United Nations or regional integration organization that subscribes to the objectives of the GGGI under Article 2.

2. No Member shall be liable, by reason of its status or participation in the GGGI, for acts, omissions or obligations of the GGGI.

---

[1] *Regional integration organization shall mean an organization constituted by sovereign states of a given region, to which its member states have transferred competence in respect of matters governed by the present Agreement.*

3. Signatory States and regional integration organizations that have not submitted an instrument of ratification, acceptance or approval to the Director-General by the time of entry-into-force of the Agreement shall, at the first session of the Assembly, have the same capacities as Members, including the right to vote and the ability to be elected to, and serve on, the Council. For the avoidance of doubt, this paragraph shall not apply in relation to subsequent sessions of the Assembly.

4. Any regional integration organization which becomes a Party to the Agreement without any of its member states being a Party shall be bound by all the obligations under the Agreement. In the case of such organizations, where one or more of its member states is a Party to the Agreement, the organizations and its member states shall decide on their respective responsibilities for the performance of their obligations under the Agreement. A separate arrangement on the modalities of the exercise of membership shall be negotiated prior to membership for regional integration organizations and subsequently approved by the Assembly.

5. In their instruments of ratification, acceptance, approval or accession, regional integration organizations shall declare the extent of their competence with respect to the matters governed by the Agreement. These organizations shall also inform the Depositary, who shall in turn inform the Parties, of any substantial modification in the extent of their competence.

**Article 6**
**ORGANS**

1. The GGGI shall have an Assembly, a Council, an Advisory Committee and a Secretariat as its principal organs.

2. Branch offices or other subsidiary organs of the GGGI may be established if the Assembly so decides as required to support its activities.

**Article 7**
**THE ASSEMBLY**

1. The Assembly is the supreme organ of the GGGI and shall be composed of Members.

2. The Assembly shall meet once every two years in ordinary sessions, or as otherwise decided by the Assembly. An extraordinary session of the Assembly shall be convened upon the initiative of one-third of its Members. Sessions of the Assembly shall take place at the headquarters of the GGGI, unless the Assembly decides otherwise.

3. The Assembly shall adopt its rules of procedure by consensus at its first session. For the avoidance of doubt, this Agreement prevails to the extent of any inconsistency between this Agreement and the rules of procedure.

4. The Assembly may grant Observer status to non-state entities such as intergovernmental organizations, private companies, research institutes and non-governmental organizations (NGOs), based on criteria agreed by the Assembly. Representatives with Observer status may engage in discussions in the Assembly but shall not have voting rights in Assembly deliberations. Further provisions relating to the participation of Observers in the Assembly may be made in the rules of procedure referred to in paragraph 3.

5. The functions of the Assembly shall include:

a. electing Members to the Council, in accordance with Article 8.2, and considering the principle of rotation;
b. appointing the Director-General who shall be nominated by the Council;
c. considering and adopting amendments to this Agreement, in accordance with Article 24;
d. advising on the overall direction of the GGGI's work;
e. reviewing progress in meeting the GGGI's objectives;
f. receiving reports from the Secretariat on strategic, operational and financial matters; and
g. providing guidance on cooperative partnerships and linkages with other international bodies in accordance with Article 16.

6. Each Member shall be entitled to one vote.

7. Members that are regional integration organizations shall, in matters for which they are responsible in accordance with Article 5.4 and 5.5, exercise their right to vote with a number of votes equal to the number of their member states that are Parties to the Agreement. The modalities of the exercise of membership rights shall be included in the separate arrangement set out in Article 5.4 to be negotiated prior to membership for regional integration organizations.

8. The Assembly shall make every effort to reach decisions by consensus. If all efforts at consensus have been exhausted, and no consensus reached, on the request by the President, decisions shall as a last resort be adopted by a simple majority of the members present and voting, except as otherwise provided in this Agreement. In addition, the adoption of decisions shall require a majority of contributing members present and voting, as well as a majority of participating members present and voting. For the avoidance of doubt, decisions may be taken by written procedure between meetings of the Assembly.

9. The Assembly shall elect one President and two Vice-Presidents with terms of two years.

10. The President, with the support of the Vice-Presidents, shall preside over the Assembly and shall carry out the duties which are entrusted to her or him.

11. The President shall be responsible to the Assembly while it is in session.

**Article 8**

**THE COUNCIL**

1. The Council shall act as the executive organ of the GGGI and shall, under the guidance of the Assembly, be responsible for directing the activities of the GGGI.

2. The Council shall consist of no more than seventeen members, as follows:

a. five contributing members elected by the Assembly;
b. five participating members elected by the Assembly;
c. five experts or non-state actors who can contribute substantially to the objectives of the GGGI, appointed by the Council;
d. the host country, which shall have a permanent seat on the Council; and
e. the Director-General without a voting right.

3. The members of the Council specified in paragraph 2 a, b and c shall serve for terms of two years, except as provided in paragraph 4.

4. The Assembly shall ensure that around half of the initial Council members elected under paragraph 2 a, b and c are elected for an initial term of one year, for the purposes of continuity of Council membership.

5. The functions of the Council, under the guidance of the Assembly, shall be to:

a. nominate a Director-General for appointment by the Assembly;
b. approve the GGGI's strategy, and review the results, monitoring and evaluation framework;
c. approve the annual work program and budget;
d. approve audited financial statements;
e. approve the admission of new members to the Advisory Committee in accordance with Article 9.2;
f. approve the criteria for country program selection, which shall be consistent with the objectives of the GGGI and based, *inter alia*, on objective criteria;
g. approve the Council Sub-Committees' membership; and
h. perform any other functions delegated by the Assembly or conferred elsewhere in this Agreement.

6. Each member of the Council shall be entitled to one vote except for the Director-General.

7. The Council shall make every effort to reach decisions by consensus. If all efforts at consensus have been exhausted, and no consensus reached, on the request by the Chair, decisions shall as a last resort be adopted by a simple majority of the members present and voting, except as otherwise provided in this Agreement. In addition, the adoption of decisions shall require a majority of contributing members present and voting, as well as a majority of participating members present and voting. For the avoidance of doubt, decisions may be taken by written procedure between meetings of the Council.

8. The Council shall adopt its rules of procedure by consensus at its first session.

9. The Council shall elect one Chair and two Vice-Chairs with terms of two years.

10. The Chair, with the support of the Vice-Chairs, shall preside over the Council and shall carry out the duties which are entrusted to her or him.

11. The Chair shall be responsible to the Council while it is in session.

12. For the effective coordination and operation, the Council may establish sub-committees including, as appropriate, a Facilitative Sub-Committee, a Human Resources Sub-Committee, a Program Sub-Committee and an Audit & Finance Sub-Committee. The Audit & Finance Sub-Committee shall be chaired by a contributing member.

## Article 9
## THE ADVISORY COMMITTEE

1. The Advisory Committee, as a consultative and advisory organ of the GGGI, shall have a key role in:

a. serving as a forum for public-private cooperation on green growth; and
b. advising the Council on the strategy and activities of the GGGI, including with regard to any synergies and linkages between the GGGI and other actors that may be pursued through Article 16.

2. The Advisory Committee shall be composed of leading, relevant experts and non-state actors. Applications for membership to the Advisory Committee shall be presented to the Director-General in writing, and shall be approved by the Council in accordance with Article 8.5 e.

3. The Advisory Committee shall meet in regular session which shall be held once a year unless it decides otherwise.

4. The Advisory Committee shall adopt its rules of procedure, and may elect a Chair and a Vice Chair.

**Article 10**

**THE SECRETARIAT AND DIRECTOR-GENERAL**

1. The Secretariat shall, under the guidance of the Council and Assembly, be the chief operational organ of the GGGI, and be headed by a Director-General.

2. The Director-General shall be nominated by the Council and appointed by the Assembly. The Director-General may participate in meetings of the Council and the Assembly, but shall not vote at such meetings.

3. The Director-General shall be appointed for an initial term of four years and may be reappointed for a further term.

4. In addition to any functions conferred on the Director-General elsewhere in this Agreement or by the Council or Assembly from time to time, the Director-General shall, under the guidance of the Council and Assembly:

a. provide strategic leadership for the GGGI;
b. prepare all necessary operational and financial documents;
c. report on the overall implementation of the GGGI's activities and bring to the attention of the Council any matter which he or she considers might impact on the fulfillment of the GGGI's objectives;
d. carry out the directions of the Assembly and the Council; and
e. represent the GGGI externally and develop strong relations with Members and other stakeholders.

5. The Secretariat shall be responsible to the Director-General and shall, *inter alia*, support the Director-General in carrying out the functions listed in paragraph 4 and the core activities of the GGGI.

6. In the performance of their duties, the Director-General, and the staff of the Secretariat shall neither seek nor receive instructions from any state or from any authority external to the GGGI. They shall refrain from any action which might reflect adversely on their position as international officials.

7. The Director-General shall appoint the staff of the Secretariat in accordance with staff regulations approved by the Council. Efficiency, competence, merit and integrity shall be the

necessary considerations in the recruitment and employment of the staff, taking into account the principle of gender equality.

**Article 11**
**WORKING LANGUAGE**

The working language of the GGGI shall be English.

